0138200008

Reçu CLT / CIH / ITH
Le 30 MARS 2017
N° 0148



English translation of inventory of Kun Bokator

## 1.10. Kbach Kun Khmer/Kun Bokator (Khmer Martial Arts)

Community or location: throughout Cambodia
Domain: Social practice, belief, religious, and ritual
Date: Unlimited

**Description:**

Before the establishment of modern weapons, *Kbach Kun Khmer* (Khmer martial arts) played a very important role for the protection of territory of Khmer Empire. Although there was no specific evidence indicating the period of its creation, but carvings on ancient Khmer temples reflecting its existence for thousands of years. Because of the importance of Kbach Kun Khmer, it became a very popular among ordinary people, monks, soldiers, and Kings who practiced this martial arts for self-defense and protection of the country. For this reason, Kbach Kun Khmer has been continued and transferred from one generation to another and what we see this form today is a testimony of its long history of thousand years.

Today, this element has various local names and most well-known called ***"Kun Bokator"***. *Kbach Kun Khmer* using hands, elbows, knees and feet, sticks or swords as the fighting techniques. According to the historical documents indicates that *Kbach Kun Khmer* has 12 sets (positions) or literally called 12 *Tvear.* These are mainly distributed into 374, such as *Me bokator, Me Khveang, Me Srob, Me Kun, Me Bak, Me Bek, Me Bit, Me Dambang, Me Dav, Me Chambab, Me Prah Atit Tro Mek, Me Isey Dork Dav, Me Paka Svay Rik, Me Top Chaveng Day, Me Sva Bos Khmom, Me Hanuman Tvay Phaka, Me Hanuman Pul Bay, Me Hanuman Tvay Khmum Prah Ream, Me Isey Krung Sbong Bambek Khan Tvea 8 etc.*

Among the 12 sets, *Kbach Kun Khmer* has divided into 3 other techniques, or *3 Khan*. The first Khan called *Atman Yut* (one to 8), this is conducted without assistant from the any combated tool during the fighting. The fighters have to use the array of elbow and knee strikes, shin kicks, like we mentioned at the pervious paragraph. The second Khan, *Horn Yut* (9 to 10), the wooden stick has been used. The last one, *Khan Yut (11* to 12) , the swords and spears are needed. Each set of the 12 are linked together as a system in 5 forms such as *Tvear, Kol, Mesorm, Kbach, Sneat.*

*Kbach Kun Khmer* is well known not only within the military but also the performing arts such as the plays of Bassac, Khol (mask dance). Furthermore, *Kbach Kun Khmer became a popular national sport, Prodal Kbach Khmer* (Khmer traditional boxing).

Refference:

Rath Sandap, 2012, "History of *Prodal Kbach Khmer, Phnom Penh.*

# ១.១០. ក្បាច់គុនខ្មែរ

*Kbach Kun Khmer (Khmer Matial Arts)*

| | |
|---|---|
| សហគមន៍ ឬ ទីតាំងប្រតិបត្តិ | ទូទាំងប្រទេស |
| ប្រភេទ | កិច្ចប្រតិបត្តិសង្គម, ជំនឿ-សាសនា, ពិធីបុណ្យ |
| ពេលវេលា | មិនកំណត់ពេល |



គុនដំបង (រូបៈ សាន ផល្លា, ២០១៥)

## ពិពណ៌នា

មុនសព្វាវុធទំនើបត្រូវគេបង្កើតឡើង ក្បាច់គុនមានតួនាទីសំខាន់ខ្លាំងណាស់សម្រាប់ការពារ ឬវាតទីពង្រីកទឹកដី។ ថ្វីត្បិតតែពុំមានតឹកតាងបញ្ជាក់ថា "ក្បាច់គុនខ្មែរ" មានកំណើតតាំងពីពេលណា តែបើមើលលើចម្លាក់នៅតាមប្រាសាទបុរាណក៏ស្មានបានថា វាមានអាយុកាលរាប់ពាន់ឆ្នាំមកហើយដែរ។ ដោយសារក្បាច់គុនមានសារៈសំខាន់ដូច្នេះហើយ ទើបតាំងពីរាស្ត្រសាមញ្ញ កងទ័ព រហូតដល់ព្រះមហាក្សត្រ ជានិច្ចកាលតែងតែសព្វព្រះទ័យនិងចូលចិត្តហាត់រៀនក្បាច់គុន ពោលគឺដើម្បីការពារខ្លួន និងការពារជាតិ។ ប្រហែលដោយសារមូលហេតុនេះហើយ ទើបបានជាមរតកវប្បធម៌អរូបីមួយនេះ ត្រូវផ្ទេរបន្តពីជំនាន់មួយទៅជំនាន់មួយទៀត រហូតមកទល់នឹងសព្វថ្ងៃ។ ម្ល៉ោះហើយ អ្វីដែលឃើញសព្វថ្ងៃនេះ គឺជាមរតកក្បាច់គុនដែលវិវត្តរាប់ពាន់ឆ្នាំមកហើយ។

សព្វថ្ងៃ ក្បាច់គុនខ្មែរអាចមានឈ្មោះហៅផ្សេងៗគ្នាតាមស្រុកតាមតំបន់ ឬតាមគ្រូគុន តែមនុស្សភាគច្រើនតែងហៅថា "ល្បុក្កតោ"។ គុនខ្មែរ ប្រើប្រាស់រាងកាយផ្ទាល់ដូចជាកណ្តាប់ដៃ, កែងដៃ, ជង្គង់ និងជើង ហើយគុនខ្លះមានដំបង ឬដាវជាអាវុធជំនួយផង។ បើតាមឯកសារ "យុទ្ធគុនខម" បង្ហាញថា យុទ្ធគុនក្បួនចម្បាំងខ្មែរមាន "១២ទ្វារ"។ ក្រៅពីនេះមានទ្វារពិសេស១ទៀតហៅថា "ទ្វារមហារំដោះ"។ ក្នុងទ្វារទាំង១២នោះ គឺមានមេប្រមាណ៣៧៤ ដូចជាៈ មេល្បុក្កតោ, មេខ្វែង, មេស្រប, មេគុន, មេបក, មេបើក, មេបិទ, មេដំបង, មេដាវ, មេចំបាប់, មេព្រះអាទិត្យទ្រមេឃ, មេឥសីដកដាវ, មេផ្កាស្វាយរីក, មេទ័ពទ្វេងដៃ, មេស្វាបោសឃ្មុំ, មេហនុមានថ្វាយផ្កា, មេហនុមានពុលបាយ, មេហនុមានថ្វាយឃ្មុំព្រះរាម, មេឥសីគ្រងស្បង់ និងបំបែកខណ្ឌទ្វារ៨ជាដើម។ ក្នុងចំណោមទ្វារទាំង១២ និងទ្វារពិសេសនេះ មានចែកចេញជា៣ខណ្ឌពោលគឺខណ្ឌទី១

ហៅ"អាត្ម័នយុទ្ធ"(ទ្វារ១ដល់៨) ជាក្បាច់គុនដែលពុំប្រើអាវុធជំនួយពោលគឺប្រើតែដៃនិងជើង, ខណ្ឌទី២ ហៅ "ហ័នយុទ្ធ" (ទ្វារ៩ ដល់១០)ជាយុទ្ធគុន ដែលប្រើដំបង និងខណ្ឌទី៣ ហៅ "ទ័ទ្ធយុទ្ធ" (ទ្វារ១១ដល់១៦) ជាយុទ្ធគុនដែលប្រើដាវនិងលំពែង។ ក្នុងទ្វារនីមួយៗមានច្រើន ក្បាច់ច្រើនស្មៀតណាស់។ ក្បាច់គុនខ្មែរមានរចនាសម្ពន្ធសំខាន់ចំនួន៥ គឺទី១ ហៅថា"ទ្វារ", ទី២ ហៅថា"គោល", ទី៣ ហៅថា"មេសម", ទី៤ ហៅថា"ក្បាច់" និងទី៥ ហៅថា"ស្មៀត"។

ក្បាច់គុនខ្មែរ បានជ្រួតជ្រាប មិនត្រឹមតែក្នុងវង្វង់កងទ័ពប៉ុណ្ណោះទេ តែក៏មានក្នុងសិល្បៈសម្តែងដែរដូចជា ល្ខោនបាសាក់ និងល្ខោនខោលជាដើម។ ពិសេសជាងនេះទៀតក្បាច់គុនខ្មែរក្លាយជាកីឡាជាតិដ៏មានប្រជាប្រិយពោលគឺ "ប្រដាល់ក្បាច់ខ្មែរ"។



គុនល្បុក្កតោ (រូប៖ សាន ផល្លា, ២០១៥)

## ឯកសារពិគ្រោះ


វ័ន្ធ សណ្តាប់, ២០១២, ប្រវត្តិប្រដាល់ក្បាច់ខ្មែរ, ភ្នំពេញ។